សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ROYAL UNIVERSITY OF PHNOM PENH
ការិយាល័យប្រឹក្សាវិជ្ជាជីវៈ CAREER ADVISING OFFICE
មជ្ឈមណ្ឌលប្រឹក្សាអប់រំ EDUCATIONAL ADVISING CENTER

# អាហារូបករណ៍នៅរៀនថ្នាក់ឧត្តមសិក្សា និងម៉ាស្ទ័រ នៅប្រទេសថៃ ឆ្នាំ២០០៩

សាកលវិទ្យាល័យនៃព្រះរាជាណាចក្រថៃ (នគររាជសីមា-ស៊ីសាកេត-មហាសារាខាម និងបូរាផា) បានសម្រេចផ្តល់ អាហារូបករណ៍ចំនួន**៥៥**កន្លែង ដល់និសិ្សតកម្ពុជា ដើម្បីទៅបន្តការសិក្សាថ្នាក់ឧត្តមសិក្សា និងម៉ាស្ទ័រ នៅប្រទេសថៃ នាដើមខែមិថុនា ឆ្នាំ២០០៩។

## I. លក្ខខណ្ឌនៃការជ្រើសរើស

### ១. ថ្នាក់ឧត្តមសិក្សា

- ជាសិស្សដែលបានប្រលងជាប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ មិនលើសពី២ឆ្នាំ (ចាប់ពីឆ្នាំ២០០៧)
- ជាសិស្សដែលពុំទាន់បានអាហារូបករណ៍ចូលរៀនក្នុងគ្រឹះស្ថានឧត្តមសិក្សាណាមួយក្នុងប្រទេស
- អាយុមិនលើសពី២៥ឆ្នាំ (គិតដល់ខែ មិថុនា ឆ្នាំ២០០៩)

* ***ចំពោះសាកលវិទ្យាល័យរាជភ័ត្តនគររាជសីមា*** *(ជាសិស្សនារីក្រីក្រ និងរៀនពូកែ មកពីវិទ្យាល័យកំពង់ឈើទាល)*

### ២. ថ្នាក់ម៉ាស្ទ័រ

- មានសញ្ញាបត្របរិញ្ញាបត្រ (ភ្ជាប់ព្រឹត្តិប័ត្រពិន្ទុ)
- មានអាយុមិនលើសពី៤០ឆ្នាំ (គិតដល់ខែ មិថុនា ឆ្នាំ២០០៩)
- មានបទពិសោធន៍ក្នុងការងាររដ្ឋ រឺក្រុមហ៊ុនឯកជន រឺអង្គការផ្សេងៗ យ៉ាងតិច៣ឆ្នាំ
- លិខិតបញ្ជាក់ពីកន្លែងធ្វើការងារ
- ចេះភាសាអង់គ្លេសជ្រៅជ្រះ
- ប្រវត្តិរូបសង្ខេប (ជាភាសាអង់គ្លេស រឺភាសាថៃ)

## II. កាលបរិច្ឆេទទទួលពាក្យ

ចាប់ពីថ្ងៃផ្សាយដំណឹងនេះតទៅ រហូតដល់ថ្ងៃទី **១២ ខែមករា ឆ្នាំ២០០៩** នៅការិយាល័យអាហារូបករណ៍ និងកម្មសិក្សានៃនាយកដ្ឋានទំនាក់ទំនងវប្បធម៌និងអាហារូបករណ៍ អាគារលេខ២៣ ផ្លូវ៣៦០ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន (ខាងកើតស្ថានីយ៍ទូរទស្សន៍អប្សរាប្រហែល៥០ម៉ែត្រ)។

**ពត៌មានបន្ថែម:** បន្ទប់ 103 អគារ A សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
ទូរស័ព្ទ: ០២៣ ៨៨៤ ៣២០ រឺ ០១១ ៨៥០ ១២១